ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
ចូល
លេខ ១១៣
ថ្ងៃទី ១៤ ខែ ១ ឆ្នាំ ២០២១
ម៉ោង ១៦:០០
បញ្ជូន ១៦ : ៣០

# ព្រះរាជក្រឹត្យ

នស/រកត/០១២១/០០៣៧

## ស្តីពី

## ការបង្កើតបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

ខុទ្ទកាល័យ
ចូល
លេខ : ១៥៧
ថ្ងៃខែឆ្នាំ : ១៥.០១.២១ ម៉ោង : ១៧:០០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើត **បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល សរសេរជាអក្សរកាត់ថា "ប.ប.ឌ." ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសគឺក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុគឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២ .-**

ប.ប.ឌ. ជានីតិបុគ្គលនៃនីតិសាធារណៈ និងមានថវិកាស្វយ័តដែលត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ប.ប.ឌ. មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្លូវជាតិលេខ៦A ភូមិខ្វរ សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

**មាត្រា៣ .-**

ប.ប.ឌ. មានបេសកកម្មដឹកនាំ គ្រប់គ្រង អភិវឌ្ឍការសិក្សាស្រាវជ្រាវ អប់រំ និងនវានុវត្តន៍លើបច្ចេកវិទ្យាឌីជីថល ព្រមទាំងចូលរួមលើកកម្ពស់ប្រព័ន្ធនវានុវត្តន៍ជាតិ។

**មាត្រា៤ .-**

ប.ប.ឌ. មានភារកិច្ចជាអាទិ៍ ដូចតទៅ៖

- ផ្តល់ការអប់រំ និងបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ បណ្ឌិត និងជំនាញវិជ្ជាជីវៈផ្នែកបច្ចេកវិទ្យានិងធុរកិច្ចឌីជីថល
- បណ្តុះបណ្តាលជំនាញ និងការគ្រប់គ្រងផ្នែកឌីជីថលតាមរយៈវគ្គបណ្តុះបណ្តាល និងវិក្រឹតការសម្រាប់មន្ត្រីរាជការនិងបុគ្គលិកក្រសួងស្ថាប័ននានារបស់រដ្ឋ
- ផ្តល់សេវាប្រឹក្សាយោបល់ និងជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងកិច្ចគាំទ្រដល់រដ្ឋាភិបាលឌីជីថល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- សិក្សា និងស្រាវជ្រាវគោលនយោបាយឌីជីថល និងអភិបាលកិច្ចឌីជីថល
- សិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល
- ជំរុញនវានុវត្តន៍ឌីជីថល
- ផ្តល់ការទទួលស្គាល់ទេពកោសល្យឌីជីថល
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាល និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ប្រគល់ជូន។

## ជំពូកទី២

## ការដឹកនាំនិងការគ្រប់គ្រង

### ផ្នែកទី១

### ក្រុមប្រឹក្សាភិបាលរបស់ ប.ប.ឌ.

**មាត្រា៥ .-**

ប.ប.ឌ. ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលជាអង្គការដឹកនាំខ្ពស់បំផុតនិងមានបេសកកម្មតម្រង់ទិសការអនុវត្តនិងត្រួតពិនិត្យសកម្មភាពការងាររបស់ ប.ប.ឌ. ក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

**មាត្រា៦ .-**

ប.ប.ឌ. មានសមាជិកក្រុមប្រឹក្សាភិបាលចំនួន ៧(ប្រាំពីរ)រូប ដែលមានសមាសភាពដូចតទៅ៖

| | |
|---|---|
| - តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - តំណាងក្រសួងមុខងារសាធារណៈ | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| - ប្រធាន ប.ប.ឌ. | សមាជិក |
| - តំណាងបុគ្គលិកនៃ ប.ប.ឌ. | សមាជិកស្វ័យប្រវត្តិ។ |

**មាត្រា៧ .-**

តំណាងបុគ្គលិកនៃ ប.ប.ឌ. ១ (មួយ) រូប គឺជាសមាជិកស្វ័យប្រវត្តិនៃក្រុមប្រឹក្សាភិបាលដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិកអចិន្ត្រៃយ៍សម្រាប់អាណត្តិ ៣ (បី) ឆ្នាំ។ តំណាងបុគ្គលិកត្រូវក្លាយជាសមាជិកស្វ័យប្រវត្តិនៃក្រុមប្រឹក្សាភិបាលចាប់ពីថ្ងៃជាប់ឆ្នោត ដោយមិនចាំបាច់មានការតែងតាំងឡើយ។ នៅពេលចប់អាណត្តិ ឬលាឈប់ពីការងារ តំណាងបុគ្គលិកនេះត្រូវបាត់បង់សមាជិកភាពក្រុមប្រឹក្សាភិបាលដោយស្វ័យប្រវត្តិ។ តំណាងបុគ្គលិកនេះត្រូវបានជ្រើសរើសដោយការបោះឆ្នោត។ អ្នកមានសិទ្ធិបោះឆ្នោតសម្រាប់៖

ក. អាណត្តិដំបូងនៃក្រុមប្រឹក្សាភិបាលគឺ បុគ្គលិកអចិន្ត្រៃយ៍។

ខ. អាណត្តិនៃក្រុមប្រឹក្សាភិបាលបន្តបន្ទាប់ទៀតគឺ បុគ្គលិកទាំងអស់ដែលមានសិទ្ធិបោះឆ្នោតតាមការសម្រេចរបស់ប្រធាន ប.ប.ឌ. ។

តំណាងនេះត្រូវជ្រើសរើសពីក្នុងចំណោមបុគ្គលិកអចិន្ត្រៃយ៍ ដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត ស្របតាមលក្ខណវិនិច្ឆ័យ ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ ហើយមានអាយុយ៉ាងតិច ២៧ (ម្ភៃប្រាំពីរ) ឆ្នាំ និងយ៉ាងច្រើន ៥៥ (ហាសិបប្រាំ) ឆ្នាំ
- បម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងក្របខ័ណ្ឌមុខងារសាធារណៈនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដោយយកចិត្តទុកដាក់ក្នុងការការពារផលប្រយោជន៍របស់ ប.ប.ឱ. និងបុគ្គលិកទាំងអស់
- មានកិរិយាមារយាទល្អ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ដែលពាក់ព័ន្ធនឹងទំនុកចិត្ត និងសមត្ថភាពប្រកបវិជ្ជាជីវៈ
- មានសមត្ថភាព និងបទពិសោធន៍វិជ្ជាជីវៈគ្រប់គ្រាន់តាមសំណូមពរ និងលក្ខខណ្ឌនៃការងាររបស់ ប.ប.ឱ.។

នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងបុគ្គលិកជាសមាជិកស្វ័យប្រវត្តិនៃក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិនីមួយៗនៃ ប.ប.ឱ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន ប.ប.ឱ.។

ក្រៅពីប្រធាន ប.ប.ឱ. និងសមាជិកក្រុមប្រឹក្សាភិបាលស្វ័យប្រវត្តិ សមាជិកក្រុមប្រឹក្សាភិបាលដទៃទៀតត្រូវមានអាណត្តិ ៣ (បី) ឆ្នាំ ដែលត្រូវបានតែងតាំងនិងបញ្ចប់ដោយអនុក្រឹត្យ តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ អាណត្តិនេះអាចបន្តសាជាថ្មីទៀតបានដោយអនុក្រឹត្យ។

**មាត្រា៨ .-**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការ ឬឥស្សរជនដែលមានលក្ខណសម្បត្តិនិងបទពិសោធន៍ ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- បម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ដែលពាក់ព័ន្ធនឹងទំនុកចិត្ត និងសមត្ថភាពប្រកបវិជ្ជាជីវៈ
- មានសមត្ថភាពជំនាញនៅក្នុងវិស័យពាក់ព័ន្ធជាអាទិ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន គ្រប់គ្រង សេដ្ឋកិច្ច អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស។

**មាត្រា៩ .-**

សមាជិកភាពនៃក្រុមប្រឹក្សាភិបាល អាចត្រូវបានបញ្ចប់មុនអាណត្តិបាន ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះបាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួង ស្ថាប័ន ឬជាតំណាងបុគ្គលិករបស់ ប.ប.ឱ. ឬមានអសមត្ថភាព សុំលាឈប់ជាលាយលក្ខណ៍អក្សរ បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ឬត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

សមាជិកក្រុមប្រឹក្សាភិបាលថ្មីដែលត្រូវបានតែងតាំងជំនួសកន្លែងទំនេរស្របតាមលក្ខខណ្ឌខាងលើ មានអាណត្តិត្រឹមអាណត្តិដែលនៅសល់របស់សមាជិកក្រុមប្រឹក្សាភិបាលដែលខ្លួនត្រូវជំនួស។

ក្រុមប្រឹក្សាភិបាលដែលចប់អាណត្តិ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួនរហូតដល់មានការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលថ្មី។ ក្រុមប្រឹក្សាភិបាលអាណត្តិថ្មី ត្រូវតែងតាំងយ៉ាងយូរបំផុត ១ (មួយ) ខែ ក្រោយអាណត្តិរបស់ក្រុមប្រឹក្សាភិបាលចាស់ត្រូវបានបញ្ចប់។ មុនអាណត្តិរបស់ក្រុមប្រឹក្សាភិបាលចាស់ត្រូវបានបញ្ចប់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវរៀបចំសំណើទៅក្រសួងស្ថាប័នជាតំណាងក្នុងក្រុមប្រឹក្សាភិបាល ដើម្បីចាត់បញ្ជូនបេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិថ្មី។

មុខងារជាប្រធានក្រុមប្រឹក្សាភិបាលនៃ ប.ប.ឌ. មានវិសមិតភាពជាមួយមុខងារជាប្រធាន ប.ប.ឌ. ។

លើកលែងតែប្រធានក្រុមប្រឹក្សាភិបាល មុខងារជាសមាជិកក្រុមប្រឹក្សាភិបាល មានវិសមិតភាពមុខងារជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាសមាជិកក្រុមប្រឹក្សាភិបាលត្រូវជាបន្ទុករបស់ ប.ប.ឌ. លើកលែងតែករណីដែលសមាជិកនោះបានប្រព្រឹត្តកំហុសដោយចេតនា ឬដោយការធ្វេសប្រហែសធ្ងន់ធ្ងរ។

សមាជិកក្រុមប្រឹក្សាភិបាលនីមួយៗត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

សមាជិកក្រុមប្រឹក្សាភិបាលមានកាតព្វកិច្ចចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ប្រកាន់ខ្ជាប់នូវគោលជំហររាយការណ៍ជាប្រចាំពីសកម្មភាពការងារក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួនជូន ក្រសួង-ស្ថាប័នដែលខ្លួនតំណាងឱ្យ គោរពក្រមសីលធម៌វិជ្ជាជីវៈ គោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់ ប.ប.ឌ.។

**មាត្រា១០ .-**

សមាសភាពក្រុមប្រឹក្សាភិបាលអាចទទួលបានលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗតាមគោលការណ៍កំណត់ជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាសភាពក្រុមប្រឹក្សាភិបាលនៃ ប.ប.ឌ. ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗខាងលើ អាចត្រូវបានផ្អាកដោយក្រសួង ស្ថាប័នដែលសមាជិកក្រុមប្រឹក្សាភិបាលនោះតំណាងឱ្យក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ ពុំគោរពអាណត្តិរបស់ខ្លួន ដូចជា ៖

១.ក្រមសីលធម៌វិជ្ជាជីវៈនិងមនសិការវិជ្ជាជីវៈ

២.បទបញ្ជាផ្ទៃក្នុងនិងបទប្បញ្ញត្តិរបស់ ប.ប.ឌ.

៣.តួនាទីនិងភារកិច្ចនៅក្នុងក្រុមប្រឹក្សាភិបាល

៤.ភារកិច្ចរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួង ស្ថាប័នដែលសមាជិកក្រុមប្រឹក្សាភិបាលនោះតំណាងឱ្យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជនដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាលដែលមានបទពិសោធន៍លើវិស័យពាក់ព័ន្ធជាអាទិ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន គ្រប់គ្រង សេដ្ឋកិច្ច អប់រំ វិទ្យាសាស្ត្រនិងបច្ចេកទេស និងតំណាងដៃគូអភិវឌ្ឍន៍នានាឱ្យចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលបាន។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

**មាត្រា១១ ..**

ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តម្រង់ទិសការអនុវត្តសកម្មភាពការងារ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ ប.ប.ឌ. ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលខ្លី មធ្យម និងវែងរបស់ ប.ប.ឌ.
- ពិនិត្យនិងអនុម័តគម្រោងថវិកានិងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ ប.ប.ឌ.
- ពិនិត្យនិងអនុម័តរបាយការណ៍គ្រប់គ្រង របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈរបស់ ប.ប.ឌ.
- ពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ ប.ប.ឌ. និងក្រមសីលធម៌វិជ្ជាជីវៈ
- កំណត់ការរៀបចំរចនាសម្ព័ន្ធនិងភារកិច្ចទូទៅរបស់អង្គភាពចំណុះរបស់ ប.ប.ឌ.
- កំណត់នីតិវិធីនៃការជ្រើសរើសបុគ្គលិក ការដំឡើងឋានន្តរស័ក្តិ ការផ្តល់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ពិនិត្យនិងអនុម័តលើសំណើសុំរបស់ប្រធាន ប.ប.ឌ. ក្នុងការកំណត់ក្របខ័ណ្ឌនិងចំនួនបុគ្គលិកប្រចាំឆ្នាំ
- ធ្វើការវាយតម្លៃលើលទ្ធផលសម្រេចបាន ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងលើកវិធានការកែតម្រូវសម្រាប់អនុវត្តបន្ត
- ពិនិត្យនិងសម្រេចលើគោលការណ៍នៃការផ្តល់សញ្ញាបត្រ វិញ្ញាបនបត្រ និងពានរង្វាន់ផ្សេងៗ ព្រមទាំងការផ្តល់ការទទួលស្គាល់ទេពកោសល្យក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាល ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល។

**មាត្រា១២ ..**

យ៉ាងយូរ ១ (មួយ) ខែក្រោយការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលអាណត្តិដំបូង ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលលើកទីមួយ ដែលរបៀបវារៈសំខាន់គឺការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ ប.ប.ឌ. ក្នុងនោះត្រូវបញ្ជាក់អំពីរចនាសម្ព័ន្ធនិងភារកិច្ចទូទៅរបស់អង្គភាពចំណុះ ប.ប.ឌ. នោះ។

ក្រុមប្រឹក្សាភិបាលនៃ ប.ប.ឌ. មានរបបប្រជុំសាមញ្ញ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងការប្រជុំវិសាមញ្ញតាមគំនិតផ្តួចផ្តើមរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬតាមការស្នើសុំពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន ២ភាគ៣ ឬពីប្រធាន ប.ប.ឌ. តាមការចាំបាច់។

សម្រាប់ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ចាំបាច់ត្រូវដាក់បញ្ចូលរបៀបវារៈរួមទាំងការអនុវត្តថវិកា ការពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ។

ប្រធាន ប.ប.ឧ. ត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយត្រូវជ្រើសរើសមន្ត្រីម្នាក់នៃ ប.ប.ឧ. ជាលេខាធិការនៃអង្គប្រជុំ។ លេខាធិការនេះ ពុំមានសិទ្ធិបោះឆ្នោតទេ។

ក្រុមប្រឹក្សាភិបាលធ្វើការពិភាក្សាលើរបៀបវារៈដែលបានគ្រោង។ របៀបវារៈត្រូវបានជូនដំណឹងមុនយ៉ាងតិច ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកពាក់ព័ន្ធដទៃផ្សេងទៀត។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលមានចែងក្នុងមាត្រា៣៧ នៃព្រះរាជក្រឹត្យនេះ អាចចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែមិនមានសិទ្ធិបោះឆ្នោតទេ។

ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលលើសពី ៥០ (ហាសិប) ភាគរយ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលអវត្តមាន ពុំអាចឱ្យគេជំនួសបានឡើយ។

ប្រសិនបើកូរ៉ុមមិនគ្រប់គ្រាន់នោះ ប្រធានក្រុមប្រឹក្សាភិបាលអាចកោះអញ្ជើញប្រជុំជាថ្មីក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃក្រោយ។ ការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានពុំបានប្រជុំតាមការអញ្ជើញលើកទី១ (មួយ) ប៉ុណ្ណោះ។

សមាជិកដែលចូលរួមប្រជុំត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវបានអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងរក្សាទុកនៅទីស្នាក់ការរបស់ ប.ប.ឧ. ដោយមានចុះហត្ថលេខារបស់ប្រធាន។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុ។ កំណត់ហេតុត្រូវឆ្លុះបញ្ចាំងពីភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ។ លេខាធិការនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវរៀបចំ និងធ្វើសេចក្តីព្រាងកំណត់ហេតុជូនសមាជិកក្រុមប្រឹក្សាភិបាលក្នុងរយៈពេល២ (ពីរ) ថ្ងៃក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំនីមួយៗ។ សមាជិកក្រុមប្រឹក្សាភិបាលមានរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទទទួលបានកំណត់ហេតុប្រជុំដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ឬផ្តល់មតិកែសម្រួលលើកំណត់ហេតុ។ ក្នុងរយៈពេល ១០(ដប់) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំ ប្រធានក្រុមប្រឹក្សាភិបាលចុះហត្ថលេខាលើកំណត់ហេតុដែលទទួលបានការកែតម្រូវ ឬការយល់ព្រមពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។

កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលខាងលើ ត្រូវបញ្ជូនក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំ ជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងជូនសមាជិកអង្គប្រជុំ។

ការប្រជុំសាមញ្ញ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ត្រូវធ្វើឡើងជាចាំបាច់ ដោយមិនត្រូវឆ្លងខែឬច្រើន[illegible]ត្រីមាស ឆមាស និងឆ្នាំ។ ការខកខានមិនបានប្រជុំក្រុមប្រឹក្សាភិបាល ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ គឺជាការទទួលខុសត្រូវផ្ទាល់របស់ប្រធានក្រុមប្រឹក្សាភិបាល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ផ្នែកទី២
# អង្គភាពប្រតិបត្តិរបស់ ប.ប.ឱ.

**មាត្រា១៣ .-**

ប.ប.ឱ. ត្រូវគ្រប់គ្រងដោយប្រធាន ១ (មួយ) រូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ។

ប្រធាន ប.ប.ឱ. ត្រូវបានតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ពីមុខតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ដោយមានការស្នើពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ប្រធាន ប.ប.ឱ. មានតួនាទីជាប្រធានអង្គភាពប្រតិបត្តិនៃ ប.ប.ឱ.។ ប្រធាន ប.ប.ឱ. ត្រូវមានសញ្ញាបត្របណ្ឌិត។ ការតែងតាំងប្រធាន ប.ប.ឱ. ត្រូវធ្វើឡើងយ៉ាងយូរ ១ (មួយ) ខែ ក្រោយពីការចូលជាធរមាននៃព្រះរាជក្រឹត្យនេះ។

អនុប្រធាន ប.ប.ឱ. ត្រូវបានតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ពីមុខតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ដោយមានការស្នើពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ អនុប្រធាន ប.ប.ឱ. ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ។ អនុប្រធាន ប.ប.ឱ. ត្រូវអនុវត្តតួនាទីនិងភារកិច្ចតាមការបែងចែកពីប្រធាន ប.ប.ឱ. ។

មុខងារជាប្រធាន និងអនុប្រធាន ប.ប.ឱ. មានវិសមិតភាពមុខងារជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា។

យ៉ាងយូរ ១ (មួយ) ខែក្រោយការតែងតាំង ប្រធាន ប.ប.ឱ. ត្រូវចាត់ចែងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង។

**មាត្រា១៤ .-**

ប្រធាន ប.ប.ឱ. ជាតំណាងរបស់ ប.ប.ឱ. ក្នុងការទំនាក់ទំនងជាមួយតតិយជន។

ប្រធាន ប.ប.ឱ. មានមុខងារនិងភារកិច្ច ដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍ ប.ប.ឱ. ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ប.ឱ. ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ ប.ប.ឱ. ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំរបាយការណ៍គ្រប់គ្រង របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈរបស់ ប.ប.ឱ. ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលស្ថិតក្រោមការកាន់កាប់និងប្រើប្រាស់របស់ ប.ប.ឱ. ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- បញ្ជូនបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតម្កល់ទុកនិងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ធ្វើការបញ្ជាក់ ក្នុងករណីចាំបាច់នូវភារកិច្ចដែលត្រូវបានប្រគល់ជូនអង្គភាពចំណុះនានានៃ ប.ប.ឧ.
- លើកសំណើរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការកំណត់មុខងារ ក្របខ័ណ្ឌ និងចំនួនមន្ត្រីរាជការនិងបុគ្គលិករបស់ ប.ប.ឧ. ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- លើកសំណើសុំលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិកគ្រប់ប្រភេទជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជាធរមាន
- បំពេញមុខងាររដ្ឋបាលនិងការគ្រប់គ្រងបន្ថែមដែលត្រូវបានប្រគល់ឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

**មាត្រា១៥ .-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃ ប.ប.ឧ. ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣

## បុគ្គលិករបស់ ប.ប.ឧ.

**មាត្រា១៦ .-**

បុគ្គលិកអចិន្ត្រៃយ៍របស់ ប.ប.ឧ. គឺជាមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈដែលត្រូវបានតែងតាំងឱ្យបម្រើការងារនៅក្នុង ប.ប.ឧ. ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តធរមាន។

ប.ប.ឧ. អាចត្រូវបានអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ខ្លួន អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បុគ្គលិក ប.ប.ឧ. ដែលមានស្នាដៃក្នុងកិច្ចការបង្រៀន និង/ឬស្រាវជ្រាវ អាចទទួលបានការវាយតម្លៃជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌសាស្ត្រាចារ្យ និង/ឬអ្នកស្រាវជ្រាវនៃ ប.ប.ឧ.។ លក្ខន្តិកៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវនៃ ប.ប.ឧ. ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

បុគ្គលិករបស់ ប.ប.ឧ. ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាផ្ទៃក្នុងដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ចំពោះមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ បទបញ្ជាផ្ទៃក្នុងស្តីពីបុគ្គលិកត្រូវអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ។

មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈដែលបំពេញភារកិច្ចនៅ ប.ប.ឧ. ទទួលបានការផ្តល់លាភការប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗពីថវិការដ្ឋ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗពីថវិការដ្ឋ ជូនបុគ្គលិកអចិន្ត្រៃយ៍និងបុគ្គលិកជាប់កិច្ចសន្យានៃ ប.ប.ឧ. ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ប្រធាន ប.ប.ឧ. បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

## ផ្នែកទី៤
## ទ្រព្យសម្បត្តិរបស់ ប.ប.ឧ.

**មាត្រា១៧ .-**

ប.ប.ឧ. ត្រូវទទួលខុសត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមលក្ខខណ្ឌកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ទ្រព្យសម្បត្តិរបស់ ប.ប.ឧ. រួមមាន៖

ក. ធនធានគ្រាដំបូងទទួលបានពីរដ្ឋ ដែលមានបញ្ជាក់ក្នុងតារាងតុល្យការភ្ជាប់ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យស្តីពីការបង្កើត ប.ប.ឧ. ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ តារាងតុល្យការនៃធនធានគ្រាដំបូងនេះ ត្រូវរៀបចំដោយគណៈកម្មការអន្តរក្រសួងរវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទទួលបានការឯកភាពពីអាណាព្យាបាលទាំងពីរ។ តារាងតុល្យការត្រូវមានភ្ជាប់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរួមជាមួយនឹងតារាងឧបសម្ព័ន្ធពាក់ព័ន្ធនានា។

ខ. ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដែលអាចរកបានក្រោយថ្ងៃបង្កើត ប.ប.ឧ. ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ប.ប.ឧ. ត្រូវបង្កើតគណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌ ដើម្បីរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់ ប.ប.ឧ. ដឹកនាំដោយប្រធាន ប.ប.ឧ.។ ប្រធាន និងសមាជិកនៃគណៈកម្មការនេះត្រូវទទួលខុសត្រូវ និងចុះហត្ថលេខាលើបញ្ជីសារពើភណ្ឌដែលបានរៀបចំរួច។ ការរៀបចំបញ្ជីសារពើភណ្ឌត្រូវបំពេញទិន្នន័យរបស់ទ្រព្យសម្បត្តិនីមួយៗឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយ ដោយអនុលោម ទៅតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប.ប.ឧ. មានកាតព្វកិច្ចរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋ កើនឡើងនិងថយចុះ ប្រចាំឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវ ដោយយកបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋភ្ជាប់នឹងតារាងតុល្យការនៃធនធានគ្រាដំបូងជាគោល រួចត្រូវផ្ញើមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) យ៉ាងយូរនៅចុងត្រីមាសទី១ នៃឆ្នាំបន្ទាប់។

ប.ប.ឧ. អាចធ្វើការទិញ លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីចលនទ្រព្យនិងអចលនទ្រព្យបាន លុះត្រាតែទ្រព្យសម្បត្តិទាំងនោះត្រូវបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ។ លក្ខខណ្ឌ និងនីតិវិធីនៃការទិញ លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីនូវទ្រព្យសម្បត្តិរដ្ឋទាំងនោះ ត្រូវស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ ហើយត្រូវស្របតាមច្បាប់នឹងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីដែល ប.ប.ឧ. ត្រូវធ្វើការរំលាយ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយព្រះរាជក្រឹត្យ ទ្រព្យសម្បត្តិដែលជាចលនទ្រព្យនិងអចលនទ្រព្យរបស់ ប.ប.ឧ. ត្រូវបង្វិលចូលជាកម្មសិទ្ធិរបស់រដ្ឋវិញ ក្រោយពីបានជម្រះបញ្ជីតាមនីតិវិធីជាធរមាន។ ចំពោះទ្រព្យសកម្មជារូបិយវត្ថុ ត្រូវបង្វែរចូលគណនីទោលរបស់រតនាគារជាតិ។

# ផ្នែកទី៥
# ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យរបស់ ប.ប.ឧ.

**មាត្រា១៨ ._**

ប.ប.ឧ. ត្រូវមានគណនេយ្យភាពចំពោះក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៩ ._**

ប្រធាន ប.ប.ឧ. ជាអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់ ប.ប.ឧ. ដែលទទួលបានការប្រគល់សិទ្ធិពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលជាអាណាប័កដើមខ្សែ ដោយមានសិទ្ធិអំណាច ដូចតទៅ៖

- បញ្ជា និងជម្រះចំណូល
- បញ្ជាចំណាយ ជម្រះបញ្ជី និងចេញអាណត្តិបើកប្រាក់។

ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ ប្រធាន ប.ប.ឧ. អាចផ្ទេរសិទ្ធិនេះឱ្យអាណាប័កជំនួស ដោយមានការយល់ព្រមពីអាណាប័កដើមខ្សែ។

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវតែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់ ប.ប.ឧ. តាមសំណើរបស់ប្រធាន ប.ប.ឧ. និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុនៅ ប.ប.ឧ. ។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម៖

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រឡើងទៅ ផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុយ៉ាងតិច ៣ (បី) ឆ្នាំ
- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២០ ._**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់បញ្ជីគណនេយ្យ ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។

គណនេយ្យករត្រូវមានគុណវុឌ្ឍិ និងបទពិសោធន៍វិជ្ជាជីវៈច្បាស់លាស់ គ្រប់គ្រាន់ ព្រមទាំងបំពេញលក្ខខណ្ឌផ្សេងទៀតដែលស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ គណនេយ្យករត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គណនេយ្យករអាចចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់។

គណនេយ្យករ មានភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រងការប្រមូលចំណូល
- ទូទាត់ចំណាយ

- រក្សាទុក និងគ្រប់គ្រងការប្រើប្រាស់នូវមូលនិធិនិងវត្ថុមានតម្លៃ
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ
- ចូលរួមរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់ ប.ប.ឧ.

គណនេយ្យករអាចមានមន្ត្រីជំនាញមួយចំនួន ជាជំនួយការក្នុងការបំពេញមុខងាររបស់ខ្លួន។

**មាត្រា២១ .-**

ប្រភពធនធានរបស់ ប.ប.ឧ. រួមមាន៖

- ធនធានដំបូងរបស់រដ្ឋផ្តល់ដល់ ប.ប.ឧ. នៅពេលចាប់ផ្តើមបង្កើតដំបូងស្របតាមមាត្រា១៩ នៃព្រះរាជក្រឹត្យនេះ
- ការផ្ទេរលក្ខណៈជាអន្តរាគមន៍សាធារណៈដែលមានគ្រោងក្នុងថវិការដ្ឋ ដូចជា ឧបត្ថម្ភធនសម្រាប់ដំណើរការនិងឧបត្ថម្ភធនជាមូលធនអំណោយ ជំនួយ និងអច្ច័យទានដែល ប.ប.ឧ. បានទទួល
- កម្រៃសេវាសាធារណៈឬភាគទានដែលប.ប.ឧ. មានសិទ្ធិប្រមូលដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- កម្រៃពីទ្រព្យសម្បត្តិរបស់ ប.ប.ឧ. និងចំណូលពីការលក់ទ្រព្យសម្បត្តិទាំងនោះស្របតាមការកំណត់នៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២២ .-**

ចំណូល ចំណាយចរន្ត និងមូលធនរបស់ ប.ប.ឧ. ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ ប.ប.ឧ. និងត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិកាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ចំណូលរបស់ ប.ប.ឧ. រួមមានការឧបត្ថម្ភពីថវិការដ្ឋ ចំណូលផ្ទាល់ និងចំណូលផ្សេងៗស្របតាមមាត្រា២១នៃព្រះរាជក្រឹត្យនេះ។

ថវិកាត្រូវរៀបចំដោយប្រធាន ប.ប.ឧ. ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យនិងអនុម័តរួចបញ្ជូនទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីពិនិត្យនិងសម្រេច មុននឹងបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអនុលោមតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ថវិកាត្រូវមានតុល្យភាពរវាងចំណូល និងចំណាយ។

ចំណូល និងចំណាយរបស់ ប.ប.ឧ. ត្រូវគោរពតាមវិធានចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចថវិកាជាតិដែរ។

ចំណាយត្រូវឆ្លុះបញ្ចាំងគ្រប់មុខសញ្ញានៃការប្រើប្រាស់ពីគ្រប់ប្រភពឥណទាន។

ប.ប.ឧ. មិនអាចបង្កើតលក្ខខណ្ឌដែលនាំឱ្យមានឱនភាពថវិកាឡើយ ក្នុងអំឡុងពេលនៃការអនុវត្តថវិកាប្រចាំឆ្នាំ លើកលែងតែមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៣ .-**

គណនេយ្យរបស់ ប.ប.ឧ. រួមមាន៖

- គណនេយ្យទូទៅ ដែលគោរពតាមគោលការណ៍ទ្វេភាគដែលឆ្លុះបញ្ចាំងគ្រប់ប្រតិបត្តិការថវិកា ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការជាមួយតតិយជន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- គណនេយ្យអចលនទ្រព្យ ទ្រព្យសកម្ម និងគណនេយ្យតម្លៃ

- គណនេយ្យវិភាគ ប្រសិនបើមានការចាំបាច់។

កិច្ចបញ្ជិកាគណនេយ្យរបស់ ប.ប.ឧ. ត្រូវរៀបចំស្របតាមវិធានទូទៅ និងប្លង់គណនេយ្យសាធារណៈ។

គោលការណ៍ណែនាំស្ដីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន និងគណនេយ្យរដ្ឋទេយ្យចំណូលរបស់ ប.ប.ឧ. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៤ ._**

ថវិការបស់ ប.ប.ឧ. គឺជាមូលនិធិសាធារណៈរបស់រដ្ឋ។

ថវិការបស់ ប.ប.ឧ. ដែលមានប្រភពឧបត្ថម្ភធនពីថវិការដ្ឋត្រូវដាក់ចូលក្នុងគណនីនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចអនុញ្ញាតឱ្យ ប.ប.ឧ. ប្រើប្រាស់គណនីនៅធនាគារពាណិជ្ជសម្រាប់គ្រប់គ្រងថវិកាដែលបានមកពីចំណូលផ្ទាល់និងពីប្រភពផ្សេងៗទៀត។

អតិរេករបស់ ប.ប.ឧ. ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល។ អតិរេកនេះត្រូវមានការបញ្ជាក់ទទួលស្គាល់ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អតិរេកនេះអាចត្រូវបានចាត់ចែងសម្រាប់ធ្វើហិរញ្ញប្បទានដល់ចំណាយប្រតិបត្តិការនាការិយបរិច្ឆេទបន្ទាប់ និង/ឬសម្រាប់ការវិនិយោគជាប្រយោជន៍ដល់ការអភិវឌ្ឍ ប.ប.ឧ. ឬជាកម្មវត្ថុនៃការបង់ចូលថវិកាជាតិ។ ការចាត់ចែងអតិរេកនេះត្រូវមានការយល់ព្រមពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៦

## របបសារពើពន្ធ ប.ប.ឧ.

**មាត្រា២៥ ._**

ប.ប.ឧ. ត្រូវស្ថិតនៅក្រោមនីតិវិធីនៃរបបសារពើពន្ធជាធរមាន លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់។

## ផ្នែកទី៧

## ការទារលទ្ធកម្មរបស់ ប.ប.ឧ.

**មាត្រា២៦ ._**

ការគ្រប់គ្រង ការអនុវត្ត និងការត្រួតពិនិត្យការងារលទ្ធកម្មក្នុង ប.ប.ឧ. ត្រូវអនុលោមតាមច្បាប់ស្ដីពីលទ្ធកម្មសាធារណៈនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

# ជំពូកទី ៣
## អាណាព្យាបាលភាព

**មាត្រា២៧ .-**

ប.ប.ឌ. មានអាណាព្យាបាលពីរ ដូចខាងក្រោម ៖

១.អាណាព្យាបាលបច្ចេកទេស គឺ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

២.អាណាព្យាបាលហិរញ្ញវត្ថុ គឺ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានអគ្គនាយកដ្ឋានថវិកា ជាសេនាធិការក្នុងការសម្របសម្រួលគ្រប់គ្រង ប.ប.ឌ. ។

**មាត្រា២៨ .-**

អាណាព្យាបាលបច្ចេកទេស និងអាណាព្យាបាលហិរញ្ញវត្ថុ អាចចាត់មន្ត្រីមានសមត្ថកិច្ចឱ្យធ្វើអធិការកិច្ច សវនកម្ម តាមដាន និងត្រួតពិនិត្យលើកិច្ចប្រតិបត្តិការនានារបស់ ប.ប.ឌ. តាមការចាំបាច់។

**មាត្រា២៩ .-**

ប.ប.ឌ. ត្រូវផ្តល់ជូនអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំ ប.ប.ឌ. ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយការពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាភិបាលលើឯកសារ ដូចខាងក្រោម៖

- កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍន៍ ប.ប.ឌ.
- គម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ប.ឌ.
- របាយការណ៍គ្រប់គ្រងរដ្ឋបាល របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ របាយការណ៍លទ្ធកម្មសាធារណៈ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ ប.ប.ឌ. ។

ពេលទទួលបានឯកសារខាងលើ អាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំ ប.ប.ឌ. ត្រូវចាត់ការតាមសមត្ថកិច្ចរៀងៗខ្លួន ស្របតាមបទប្បញ្ញត្តិជាធរមាន។

### ផ្នែកទី១
### អាណាព្យាបាលបច្ចេកទេស

**មាត្រា៣០ .-**

អាណាព្យាបាលបច្ចេកទេស មានភារកិច្ច ដូចខាងក្រោម៖

- កំណត់គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់ ប.ប.ឌ. អនុវត្ត
- ពិនិត្យនិងសម្រេចផែនការអភិវឌ្ឍន៍របស់ ប.ប.ឌ.
- ពិនិត្យនិងសម្រេចលើសេចក្តីព្រាងនៃគម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ប.ឌ.
- ពិនិត្យនិងសម្រេចលើសំណើចាត់ចែង ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងជម្រះបញ្ជីសារពើភណ្ឌ

- ត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលនៃការអនុវត្តផ្នែកបច្ចេកទេសរបស់ ប.ប.ឱ.
- ដាក់ចេញនូវវិធានការកែលម្អនានាពាក់ព័ន្ធនឹងការអនុវត្តផ្នែកបច្ចេកទេសរបស់ ប.ប.ឱ.
- លើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចអំពីការរៀបចំនិងការប្រព្រឹត្តទៅនៃ ប.ប.ឱ. តាមការស្នើសុំរបស់ក្រុមប្រឹក្សាភិបាល ប.ប.ឱ.
- ស្នើតែងតាំងប្រធាន ប.ប.ឱ.
- តែងតាំងមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅ ប.ប.ឱ. អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- តែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់ ប.ប.ឱ. ។

**មាត្រា៣១ .-**

អនុលោមតាមបទប្បញ្ញត្តិជាធរមាន អាណាព្យាបាលបច្ចេកទេសត្រូវផ្ញើជូនអាណាព្យាបាលហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរ នូវការសម្រេចទាំងឡាយរបស់ខ្លួន និងរបស់ក្រុមប្រឹក្សាភិបាលដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដើម្បីពិនិត្យនិងសម្រេច ដូចខាងក្រោម៖

- ផែនការអភិវឌ្ឍន៍ ប.ប.ឱ.
- គម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ប.ឱ.
- ការចាត់ចែង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- សេចក្តីសម្រេចស្តីពីការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- សេចក្តីសម្រេចផ្សេងទៀតដែលអាចមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ។

**មាត្រា៣២ .-**

អាណាព្យាបាលបច្ចេកទេស មានសិទ្ធិលុប ឬផ្អាកការអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធនឹង ប.ប.ឱ. ក្នុងករណីដែល៖

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬប្រធាន ប.ប.ឱ. ផ្ទុយនឹងគោលនយោបាយ ឬយុទ្ធសាស្ត្ររបស់ ប.ប.ឱ. ក៏ដូចជារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលឬរបស់ ប.ប.ឱ. ផ្ទុយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សេចក្តីសម្រេចធ្វើឡើងដោយក្រសួង ស្ថាប័ន អាជ្ញាធរ ដែលមិនមានសមត្ថកិច្ចតាមផ្លូវច្បាប់ ឬសេចក្តីសម្រេចធ្វើឡើងដោយការប្រជុំក្រុមប្រឹក្សាភិបាលដែលពុំអនុលោមតាមនីតិវិធី
- សេចក្តីសម្រេចមានការពាក់ព័ន្ធនឹងបណ្តឹងផ្សេងៗ ដែលពុំទាន់បានដោះស្រាយរួច។

ការលុបចោល ឬការផ្អាកខាងលើនេះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយមានបញ្ជាក់ពីមូលហេតុច្បាស់លាស់។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវជូនដំណឹងនៃប្រកាសនេះដល់ប្រធាន ប.ប.ឱ.។ ប្រធាន ប.ប.ឱ. ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលឆាប់បំផុត។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៣៣ .-**

ក្នុងករណីដែលក្រុមប្រឹក្សាភិបាលឬប្រធាន ប.ប.ឱ. ពុំប្រតិបត្តិតាមបណ្ដាវិធានដែលមានចែងក្នុងច្បាប់ឬបទប្បញ្ញត្តិនិងបទបញ្ជាផ្ទៃក្នុងរបស់ ប.ប.ឱ. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចចេញសេចក្ដីសម្រេចនិងអាចប្រើប្រាស់វិធានការចាំបាច់ទាំងអស់ បន្ទាប់ពីបានធ្វើការណែនាំនិងដាក់កំហិតជាលាយលក្ខណ៍អក្សររួចមក។

## ផ្នែកទី២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា៣៤ .-**

អាណាព្យាបាលហិរញ្ញវត្ថុ មានភារកិច្ចៈ

- ពិនិត្យនិងផ្ដល់ការយល់ព្រមលើផែនការអភិវឌ្ឍន៍ ប.ប.ឱ.
- ពិនិត្យនិងសម្រេចលើគម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ប.ឱ.
- ពិនិត្យនិងអនុម័តផែនការលទ្ធកម្មរបស់ ប.ប.ឱ.
- ពិនិត្យនិងសម្រេចលើការចាត់ចែង ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ
- ពិនិត្យនិងផ្ដល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ពិនិត្យនិងសម្រេចលើសេចក្ដីសម្រេចស្ដីពីការផ្ដល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- ពិនិត្យនិងសម្រេច ឬផ្ដល់ការយល់ព្រមលើឯកសារផ្សេងទៀត តាមសំណើរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឬប្រធាន ប.ប.ឱ. ស្របតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំ និងដាក់ឱ្យអនុវត្តវិធាននិងនីតិវិធីចំណូល ចំណាយ បទដ្ឋានចំណូល ចំណាយ និងបទដ្ឋានគតិយុត្តទាំងឡាយដទៃទៀតពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់ ប.ប.ឱ. ។

**មាត្រា៣៥ .-**

សេចក្ដីសម្រេចរបស់ប្រធាន ប.ប.ឱ. របស់ក្រុមប្រឹក្សាភិបាល និងរបស់អាណាព្យាបាលបច្ចេកទេសដែលពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា៣៤ នៃព្រះរាជក្រឹត្យនេះ ពុំមានអានុភាពអនុវត្តឡើយ ក្នុងករណីដែលពុំមានការយល់ព្រមពីអាណាព្យាបាលហិរញ្ញវត្ថុ។

ក្នុងករណីអាណាព្យាបាលហិរញ្ញវត្ថុជំទាស់លើសេចក្ដីសម្រេច ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ អាណាព្យាបាលហិរញ្ញវត្ថុ ត្រូវផ្ញើជូនអាណាព្យាបាលបច្ចេកទេស និងប្រធាន ប.ប.ឱ. នូវការជំទាស់របស់ខ្លួនដោយបញ្ជាក់នូវមូលហេតុច្បាស់លាស់។ ប្រធាន ប.ប.ឱ. និងក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេសត្រូវពិនិត្យនិងដោះស្រាយឱ្យបានឆាប់បំផុត នូវករណីដែលបានលើកឡើងនោះដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៣៦ .-**

អាណាព្យាបាលហិរញ្ញវត្ថុអាចលុបឬផ្អាកការអនុវត្តសេចក្តីសម្រេចចិត្តពាក់ព័ន្ធទិដ្ឋភាពហិរញ្ញវត្ថុរបស់ប្រធាន ប.ប.ឌ. ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ក្នុងករណីដែលៈ

- សេចក្តីសម្រេចរបស់ប្រធាន ប.ប.ឌ. ឬក្រុមប្រឹក្សាភិបាល ឬអាណាព្យាបាលបច្ចេកទេសផ្ទុយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត
- សេចក្តីសម្រេចមានការពាក់ព័ន្ធនឹងបណ្តឹងផ្សេងៗ ដែលពុំទាន់បានដោះស្រាយរួច។

ការលុបចោល ឬការផ្អាកទុកនេះ ត្រូវមានបញ្ជាក់ពីមូលហេតុច្បាស់លាស់និងត្រូវជូនដំណឹងដល់អាណាព្យាបាលបច្ចេកទេសនិងប្រធាន ប.ប.ឌ. ដែលត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា៣៧ .-**

អាណាព្យាបាលហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ១ (មួយ) រូប ប្រចាំ ប.ប.ឌ. ដើម្បីបំពេញមុខងារ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៤

## ការត្រួតពិនិត្យ

**មាត្រា៣៨ .-**

ប.ប.ឌ. ត្រូវមានអង្គភាពសវនកម្មផ្ទៃក្នុង ដែលត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

**មាត្រា៣៩ .-**

ប.ប.ឌ. ត្រូវស្ថិតក្រោមការធ្វើអធិការកិច្ច សវនកម្ម តាមដាន និងត្រួតពិនិត្យ ដោយអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ ស្របតាមច្បាប់ជាធរមាន។

ក្នុងករណីចាំបាច់ ប.ប.ឌ. អាចត្រូវបានតម្រូវឱ្យស្ថិតក្រោមការធ្វើសវនកម្ម ដោយសវនករឯករាជ្យដែលមានការទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា៤០ .-**

មន្ត្រី បុគ្គលិក និងធនធានទ្រព្យសម្បត្តិទាំងអស់របស់វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ត្រូវបានផ្ទេរមក ប.ប.ឌ. ។

ចំពោះលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការអនុវត្ត ការបង្កើត និងការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៤១ .-**

អនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ស្តីពីការប្រែក្លាយវិទ្យាស្ថានជាតិប្រៃសណីយ៍ និងទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤២ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ អង្គារ ៤ រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត.០១២១.០០៥

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**